# ព្រះរាជក្រឹត្យ

នស/រកត/០៤២៣/២០២៤

## ស្តីពី

## ការបង្កើតមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ .-**

ត្រូវបានបង្កើត **"មជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន"** ហៅកាត់ថា "ម.ប.ព." ដើម្បីជាយន្តការក្នុងការគ្រប់គ្រង ស្រាវជ្រាវ ប្រមូល និងវិភាគព័ត៌មានផ្នែកសន្តិសុខជាតិ ក្នុងគោលដៅដើម្បីប្រឆាំងអំពើភេរវកម្ម និងឧក្រិដ្ឋកម្មនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

មជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន ចំណុះឱ្យទីស្តីការគណៈរដ្ឋមន្ត្រី និងក្រោមការបញ្ជា និងដឹកនាំផ្ទាល់របស់នាយករដ្ឋមន្ត្រី។

**មាត្រា៣ .-**

មជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មានមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មានវិទ្យាគ្រប់ប្រភេទដែលពាក់ព័ន្ធនឹងវិស័យសន្តិសុខជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការនាំចូល និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មានវិទ្យាគ្រប់ប្រភេទដែលពាក់ព័ន្ធនឹងវិស័យសន្តិសុខជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែមានការសម្រេចយល់ព្រមពីនាយករដ្ឋមន្ត្រី។

ROYAUME ... BODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៤ .-**

មជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន មានតួនាទី និង ភារកិច្ច ដូចខាងក្រោម៖

- ជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការស្រាវជ្រាវ ប្រមូល និងចងក្រងព័ត៌មានដែលពាក់ព័ន្ធនឹងវិស័យសន្តិសុខជាតិ ក្នុងគោលដៅប្រឆាំងអំពើភេរវកម្ម និងឧក្រិដ្ឋកម្មនៅព្រះរាជាណាចក្រកម្ពុជា
- វិភាគព័ត៌មាន និងវាយតម្លៃអំពីសភាពការណ៍សន្តិសុខជាតិ ជូននាយករដ្ឋមន្ត្រី សម្រាប់ការដាក់ចេញនូវវិធានការចាំបាច់នានា សំដៅបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើភេរវកម្ម និងឧក្រិដ្ឋកម្មនៅព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងភាគីពាក់ព័ន្ធនានា ក្នុងការស្រាវជ្រាវ និងប្រមូលព័ត៌មានដែលបម្រើឱ្យវិស័យសន្តិសុខជាតិ ការប្រឆាំងអំពើភេរវកម្ម និងឧក្រិដ្ឋកម្មនានា
- សហការស្រាវជ្រាវ និងផ្តល់ព័ត៌មានជូនស្ថាប័នអនុវត្តច្បាប់ពាក់ព័ន្ធ ក្នុងប្រតិបត្តិការប្រឆាំងនឹងឧក្រិដ្ឋកម្ម
- ជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការដឹកនាំ និងសម្របសម្រួលការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មានវិទ្យាគ្រប់ប្រភេទ ដែលពាក់ព័ន្ធនឹងវិស័យសន្តិសុខជាតិ
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់នាយករដ្ឋមន្ត្រី។

**មាត្រា៥ .-**

មជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន តាមការចាំបាច់។ ប្រធាន និងអនុប្រធានមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី។

មជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដើម្បីគាំទ្រដល់កិច្ចដំណើរការរបស់ខ្លួន។ ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន ត្រូវកំណត់ដោយអនុក្រឹត្យ។

មន្ត្រីដែលបំពេញការងារនៅមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន និងនៅអគ្គលេខាធិការដ្ឋាន នៃមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន គឺជាមន្ត្រីរាជការក្របខណ្ឌនៃទីស្តីការគណៈរដ្ឋមន្ត្រី ឬក្រសួង ស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាល។ អគ្គលេខាធិការដ្ឋាននៃមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន អាចមានមន្ត្រីជាប់កិច្ចសន្យាតាមការចាំបាច់។

**មាត្រា៦ .-**

មជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន មានត្រាដោយឡែកសម្រាប់ប្រើប្រាស់ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន ដែលកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧ .-**

មជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មានមានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក ក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មានមានសិទ្ធិប្រើប្រាស់នូវមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងប្រភពស្របច្បាប់ផ្សេងទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិក ដែលបំពេញការងារនៅមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន និងនៅអគ្គលេខាធិការដ្ឋាននៃមជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន ទទួលប្រាក់បំណាច់ និងរបបឧបត្ថម្ភបន្ថែមនានាដែលកំណត់ដោយអនុក្រឹត្យ សម្រាប់ការបំពេញការងាររបស់ខ្លួន។

**មាត្រា៨ .-**

ចលនទ្រព្យ អចលនទ្រព្យ ព្រមទាំងប្រព័ន្ធ និងឧបករណ៍បច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មានវិទ្យា នៃនាយកដ្ឋានស៊ើបការណ៍ខាងក្រៅ និងបច្ចេកទេសនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវផ្ទេរឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន។

មន្ត្រីរាជការ និងបុគ្គលិក ដែលកំពុងបំពេញការងារពាក់ព័ន្ធនឹងការអនុវត្តមុខការនៃអង្គភាពដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវផ្ទេរ ទាំងក្របខណ្ឌ និងការងារ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់មជ្ឈមណ្ឌលជាតិបច្ចេកវិទ្យាព័ត៌មាន។

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០២៣

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

នស/រកត/០៨២៣/០១៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**កិត្តិទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត**